# ពិភពលោកកំពុងតែបង្ហាញថា ម៉ាទីន លូធ័រ ឃីង និយាយត្រូវពាក់ព័ន្ធនឹងអំពើអហិង្សា

## How the world is proving Martin Luther King right about nonviolence

**Erica Chenoweth and Maria J. Stephan**

Washington Post, January 18, 2016

# ពិភពលោកកំពុងតែបង្ហាញថា ម៉ាទីន លូទ័រឃីង និយាយត្រូវពាក់ព័ន្ធនឹងអំពើអហិង្សា

ដោយ៖ អេរីកា ឈើណូវិត និង ម៉ារៀ ជេ. ស្ទេហ្វេន ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦



សកម្មជនជនជាតិយេមែន តាវ៉ាកុល (រូបភាពខាងស្តាំ ក្រម៉ាពណ៌ស) ត្រូវបានទទួលរង្វាន់ណូបែលសន្តិភាព សម្រាប់សកម្មភាពដោយអហិង្សាដើម្បីសិទ្ធិស្ត្រី។ រូបភាពផ្ញើជូនដោយ៖ ស៊ូដាសាន វ៉ាហ្គាវ៉ាន

*«ខ្ញុំចាកចេញពីប្រទេសឥណ្ឌា ដោយមានជំនឿជាក់ជាងពេលណាៗទាំងអស់ថា ការតស៊ូដោយអហិង្សាគឺជាអាវុធដ៏មានអំណាចខ្លាំងបំផុត ដែលបុគ្គលរងការគាបសង្កត់អាចធ្វើបាន ក្នុងការខិតខំប្រឹងប្រែងដើម្បីទាមទាររកសេរីភាពរបស់ពួកគេ។» - «ជីវប្រវត្តិរបស់ ម៉ាទីន លូទ័រ ឃីង» កែសម្រួលដោយ ក្លេប៊ិន ខាសុន*

ចាប់តាំងពីឆ្នាំ២០១១ ពិភពលោកបានក្លាយទៅជាកន្លែងដែលចម្រូងចម្រាស់បំផុត។ ទោះបីជាមានការបះបោរប្រដាប់អាវុធផ្ទុះឡើងពាសពេញមជ្ឈឹមបូព៌ា នៅសាហេល និងអាស៊ីខាងត្បូងក៏ដោយ ក៏ជម្លោះស៊ីវិលដែលប្រើហិង្សាមិនមែនជាមធ្យោបាយចម្បង ដែលមនុស្សប្រើប្រាស់ដើម្បីកំចាត់ភាពសោកសៅរបស់ពួកគេនោះដែរ។ ផ្ទុយទៅវិញ យើងឃើញថានៅ ទីក្រុងទុយនីស ឬក៏ទីលានតាហរៀរ សួនហ្សូគូតទី ឬក៏ហ្វីហ្គូសាន់ ប៊ូគីណាហ្វាសូ ឬក៏ហុងកុង មានចលនានៅជុំវិញពិភពលោកបានទាញយកមេរៀនរបស់ គន្ធី ឃីង និងសកម្មជនដទៃទៀត ទាំងក្នុងនិងក្រៅប្រទេស ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ។

ការផ្តោតសំខាន់របស់ គន្ទី និងឃីង ទៅលើការតស៊ូដោយអហិង្សា ដោយប្រជាពលរដ្ឋដែលគ្មានអាវុធប្រើប្រាស់នូវការធ្វើកូដកម្ម បាតុកម្ម ពហិកា ឬក៏សកម្មភាពផ្សេងទៀតដើម្បីប្រឈមមុខនឹងគូប្រជែង គឺមិនមែនថាគ្មានអ្នករិះគន់នោះទេ។ អ្នករិះគន់ខ្លះ រិះគន់ដោយផ្អែកទៅលើការយល់ខុសរបស់ខ្លួនអំពីអ្វីដែលហៅថា ជាការតស៊ូដោយពលរដ្ឋ ខណៈដែលអ្នកផ្សេងទៀត លើកឡើងពីការមិនទុកចិត្តចំពោះលទ្ធភាពរបស់បុគ្គលដែលគ្មានអាវុធ និងរងការគាបសង្កត់ ក្នុងការរៀបចំ និងតវ៉ាប្រឆាំងនឹងគូប្រជែងដែលមានអំណាច។ ចលនាថ្មីៗនីមួយៗ តែងតែមានការប្រឈមស្រដៀងៗគ្នា រួមទាំងសំណួរទាក់ទងនឹងប្រសិទ្ធភាពនៃសកម្មភាពអហិង្សា ទល់នឹងអំណាចចាក់ឫសគល់ និងការគាបសង្កត់ជាប្រព័ន្ធ។ ក្នុងឆ្នាំ២០១១ យើងបានបោះពុម្ពផ្សាយសៀវភៅមួយក្បាល បើពិនិត្យលើសំណួរទាំងអស់នេះ និងបានរកឃើញដោយចៃដន្យថា យុទ្ធនាការនៃការតស៊ូដោយអហិង្សាបានទទួលជោគជ័យ ជាងការតស៊ូដោយប្រើហិង្សាដល់ទៅពីរដង ក្នុងការដកអ្នកដឹកនាំដែលកំពុងកាន់អំណាច ឬទទួលបាននូវឯករាជ្យភាពទឹកដី។

សម្រាប់មនុស្សជាច្រើននាក់ ការសន្និដ្ឋាននេះហាក់ដូចជារឿងឆោតល្ងង់ ប៉ុន្តែពេលដែលយើងមើលទិន្នន័យកាន់តែស៊ីជម្រៅ យើងរកឃើញថាយុទ្ធនាការតស៊ូដោយអហិង្សា មិនមែនជោគជ័យដោយការធ្វើឱ្យបេះដូងរបស់គូប្រជែងនោះទន់ជ្រាយនោះទេ។ ផ្ទុយទៅវិញ ការធ្វើបែបនោះអាចនឹងទទួលបានជោគជ័យ ដោយសារតែវិធីសាស្ត្រអហិង្សាអាចមានសក្តានុពលច្រើនជាង ក្នុងការទាក់ទាញឱ្យមានការចូលរួមទ្រង់ទ្រាយធំពីសាធារណជន ជាទូទៅការធ្វើបែបនេះទាក់ទាញការចូលរួមទ្រង់ទ្រាយធំពីសាធារណជន ជាងការបះបោរដោយប្រដាប់អាវុធដល់ទៅ ១១ដង ហើយដោយសារតែសាធារណជនគឺជាប្រភពចម្បង ដែលធ្វើឱ្យមានការផ្លាស់ប្តូរអំណាចក្នុងរបបគូប្រជែង។ ការចូលរួមទ្រង់ទ្រាយធំរបស់សាធារណជន ដែលបានទាក់ទាញឱ្យមានការចូលរួមពីផ្នែកផ្សេងៗ ក្នុងសង្គមដើម្បីផ្តល់សិទ្ធិអំណាច និងជ្រើសតាំងអ្នកធ្វើកំណែទម្រង់ជាច្រើន ស្របពេលដែលកំពុងកាត់ផ្តាច់បុគ្គលដែលជឿ ងប់ងល់ចេញពីប្រភពនៃការគាំទ្រ។ នៅពេលដែលមានការចូលរួមដោយអហិង្សា វានឹងបង្កើនឱកាសក្នុងការទាក់ទាញការគាំទ្រនៃរបប ពីអ្នកដឹកនាំដែលអនុញ្ញាតឲ្យកងកម្លាំងសន្តិសុខ ឥស្សរជនសេដ្ឋកិច្ច និងមន្ត្រីរាជការស៊ីវិល ដើម្បីផ្លាស់ប្តូរការគាំទ្ររបស់ពួកគេដោយពុំសូវភ័យខ្លាចថានឹងមានការបង្ហូរឈាម។

ក្នុងន័យមួយទៀត យើងរកឃើញថាការតស៊ូដោយអហិង្សាមានប្រសិទ្ធភាព ពុំមែនដោយសារតែសក្តានុពលនៃការបង្វែរដាននៃទង្វើនេះនោះទេ ប៉ុន្តែគឺដោយសារតែសក្តានុពលនៃ ភាពច្នៃប្រឌិត សិទ្ធិសម្រេចដោយខ្លួនឯង និងការប្រើប្រាស់កម្លាំង ដែលជាទ្រឹស្តីរបស់ស្ថាបនិកនៃវិទ្យាស្ថាន អាល់បឺត អាញស្តាញ លោក យីន សាប បានបញ្ជាក់យ៉ាងច្បាស់ជាច្រើនទស្សវត្សរ៍មកហើយ។ ជាធម្មតា មិនមែនរាល់យុទ្ធនាការអហិង្សាទាំងអស់សុទ្ធតែទទួលបានជោគជ័យនោះទេ។ ប៉ុន្តែក្នុងករណីដែលយុទ្ធនាការទាំងនោះបរាជ័យ ក៏ពុំមានភស្តុតាងជាប្រព័ន្ធណាមួយដែលអាចអះអាងបានថា ការបះបោរដោយហិង្សានឹងអាចធ្វើទៅបានដោយទទួលជោគជ័យនោះដែរ។

នៅពេលនោះគឺឆ្នាំ២០១១ តែឥឡូវនេះ ឆ្នាំ២០១៦ ទៅហើយ។ តើអ្វីដែលយើងបានរៀនអំពីការតស៊ូដោយអហិង្សាក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ? ខាងក្រោមនេះ យើងបានគូសវាសបង្ហាញនូវចំណុចដែលអាចរៀនបាន ដោយ

ផ្អែកលើបទពិសោធន៍ ចេញពីវិទ្យាសាស្ត្រនយោបាយ ហើយដែលចំណុចខ្លះបានបង្ហាញនូវការជាប់ទាក់ទិនដែលគួរឲ្យភ្ញាក់ផ្អើល សម្រាប់បុគ្គលដែលមានការសង្ស័យចំពោះទង្វើអហិង្សា។

## ១. យុទ្ធនាការអហិង្សាបានក្លាយជាសកម្មភាពកាន់តែសាមញ្ញ

ប្រសិនបើអ្នកមានអារម្មណ៍ហាក់ដូចជារស់នៅក្នុងពេលវេលា ដែលបង្កឱ្យមានការអាក់ខានខ្លាំងបំផុតនៅក្នុងប្រវត្តិសាស្ត្រនោះ អ្នកគិតត្រូវហើយ។ ប៉ុន្តែ ប្រភេទនៃការអាក់ខាននេះគឺពិសេសក្នុងពេលវេលារបស់យើង។ គម្រោងវគ្គសំខាន់នៃការប្រកួតប្រជែង (គម្រោងទិន្នន័យដែលដឹកនាំដោយសាស្ត្រាចារ្យ អេរីកា ឈើណូវិត នៅឯសាកលវិទ្យាល័យដេនវើ) បានស្នើថាយុទ្ធនាការតស៊ូដោយអហិង្សា បានក្លាយទៅជាប្រភេទនៃទម្រង់សកម្មភាពចម្រូងចម្រាស់នៅទូទាំងពិភពលោក។ គម្រោងទិន្នន័យ ណាវកូ ដែលជាគម្រោងប្រមូលផ្តុំទិន្នន័យដាច់ដោយឡែកមួយប្រើប្រាស់ប្រភពទិន្នន័យផ្សេង និងលក្ខខណ្ឌរួមបញ្ចូលផ្សេង បានបង្ហាញពីលំនាំស្រដៀងគ្នាទៅនឹងបណ្តុំទិន្នន័យបាតុកម្មផ្សេងទៀតដែរ។ ខណៈពេលដែលភាពញឹកញាប់នៃការបះបោរដោយហិង្សា បានឱ្យនិយមន័យចំពោះការតស៊ូដែលមានអ្នកស្លាប់ចំនួនត្រឹម ១០០០ នាក់ មានការធ្លាក់ចុះតាំងពីទស្សវត្សរ៍ឆ្នាំ១៩៧០ យុទ្ធនាការដែលផ្អែកលើការតស៊ូដោយអហិង្សាបានកើនឡើងលើសលុប។ សូមកត់សម្គាល់ថាតួលេខទាំងនេះសំដៅជាពិសេសទៅលើយុទ្ធនាការអតិបរមានិយម មានន័យថាគោលបំណងរបស់ពួកគេគឺដើម្បីដកនូវថ្នាក់ដឹកនាំកាន់អំណាចចេញពីតំណែង ឬក៏បង្កើតនូវដែនដីឯករាជ្យ តាមរយៈ ការផ្តាច់ខ្លួន ឬការបណ្តេញយោធាបរទេសដែលកាន់កាប់ ឬក៏អំណាចអាណានិគម។



ក្នុងអំឡុងពេល ៥ឆ្នាំដំបូងនៃទសវត្សរ៍បច្ចុប្បន្ន យើងមើលឃើញថាមានការចាប់ផ្តើមនៃយុទ្ធនាការអហិង្សាថ្មីៗ ជាងអំឡុងទសវត្សរ៍ទី៩០ទៅទៀត ហើយមានចំនួនប្រហាក់ប្រហែលនឹងអ្វីដែលយើងបានឃើញ ក្នុងអំឡុងឆ្នាំ ២០០០។ ទសវត្សរ៍បច្ចុប្បន្ន គឺកំពុងតែឆ្ពោះទៅរកទសវត្សរ៍ដែលចម្រូងចម្រាស់បំផុត នៅក្នុងប្រវត្តិសាស្រ្ត។

**២. បើទោះបីជាសកម្មភាពទាំងនោះជារឿងសាមញ្ញ ប៉ុន្តែអត្រាជោគជ័យទាំងស្រុងនៃយុទ្ធនាការតស៊ូដោយអហិង្សាមានការធ្លាក់ចុះ**

ស្របពេលជាមួយនឹងការកើនឡើងនៃយុទ្ធនាការអហិង្សា យើងក៏បានឃើញនូវបន្ទាត់កោងនៃការរៀនសូត្រផងដែរ។ អត្រាជោគជ័យនៃការតស៊ូដោយអហិង្សាកើនឡើងខ្ពស់បំផុតក្នុងទសវត្សរ៍ទី៩០ ប៉ុន្តែ ទសវត្សរ៍បច្ចុប្បន្ន យើងឃើញការថយចុះយ៉ាងគំហុកនៃអត្រាជោគជ័យនៃការតស៊ូដោយអហិង្សា។




មានមូលហេតុមួយចំនួននៃការធ្លាក់ចុះនេះ។ ចំណុចទីមួយ គូប្រជែងដែលជារដ្ឋប្រហែលជាបានរៀនសូត្រពីបទពិសោធន៍ និងសម្របខ្លួនដើម្បីប្រឈមតតាំងពីថ្នាក់ក្រោម។ ថ្វីបើប៉ុន្មានទសវត្សរ៍កន្លងមក ពួកគេអាចនឹងមើលស្រាលចំពោះសក្តានុពលភាពនៃអំណាចប្រជាពលរដ្ឋ ថាអាចនឹងបង្កហានិភ័យធំធេងចំពោះការដឹកនាំរបស់ពួកគេ តែឥឡូវពួកគេប្រហែលជាឃើញហើយថាយុទ្ធនាការអហិង្សារបស់សាធារណជន ពិតជាគួរឱ្យខ្លាច ដូច្នេះពួកគេបានចំណាយធនធានច្រើនជាងមុនដើម្បីការពារខ្លួនពីយុទ្ធនាការទាំងនោះ ហើយប្រហែលជាអាចនឹងធ្វើតាមការលើកឡើងរបស់ ប្រ៊ូស ប៊ូណូ ដឺ មេគ្វីតា និងអាឡាស្ទ័រ ស្មីត «សៀវភៅមគ្គុទេសក៏សម្រាប់ជនផ្តាច់ការ» ឬ

ក៏ការដាក់ចេញនូវ «ការគាបសង្កត់ដ៏ឆ្លាតវៃ» ដើម្បីបង្វែរដាននៅពេលដែលពួកគេងើបឡើងបះបោរ។ បាតុកូតនៃការសម្របសម្រួលដែលបានរៀនសូត្រពីបទពិសោធន៍ ឬជាអ្វីដែល ស្ទីវិន ហេដឺម៉ែន ប្រធាន កិតឆែម នៅក្នុងការសិក្សាពីមជ្ឈឹមបូព៌ា នៅសាកលវិទ្យាល័យ ស្ទឹត បានហៅថា «អំណាចផ្តាច់ការ ២.០» ដែលជាចំណុចផ្តោតសំខាន់នៃគម្រោង «អនាគតនៃអំណាចផ្តាច់ការ» នៅឯក្រុមប្រឹក្សាអាត្លង់ទិក។

ចំណុចទីពីរ សកម្មជនដែលប្រើប្រាស់វិធីសាស្ត្រអហិង្សា ប្រហែលជាទទួលបានមេរៀនដែលមិនត្រឹមត្រូវពីយុទ្ធនាការផ្សេងៗទៀតនៅលើពិភពលោក។ ឧទាហរណ៍ បុគ្គលម្នាក់ប្រហែលជាអាចនឹងគិតថា ផ្អែកលើការផ្សាយព័ត៌មាននៃការធ្វើបាតុកម្មទ្រង់ទ្រាយធំ និងកូដកម្មនៅ ទុយនីស៊ី ក្នុងឆ្នាំ២០១០ និង២០១១ ថាការធ្វើបាតុកម្មរយៈពេល ៣សប្តាហ៍ពេញអាចដកជនផ្តាច់ការចេញពីអំណាចបាន។ ប៉ុន្តែ ការយល់បែបនោះ ពុំបានពិចារណាទាល់តែសោះចំពោះការពិតដែលថាប្រទេសទុយនីស៊ី មានប្រវត្តិសាស្ត្រខុសគេ ក្នុងពេលថ្មីៗពាក់ព័ន្ធនឹងសកម្មភាពពលករដែលត្រូវបានរៀបចំយ៉ាងស្វាហាប់ ដែលរួមចំណែកដល់ការងើបបះបោរនេះ ហើយការធ្វើកូដកម្មទូទៅគំរាមកំហែងក្នុងការធ្វើឱ្យសេដ្ឋកិច្ចរបស់ទុយនីស៊ីគាំង ដែលធ្វើឱ្យឥស្សរជនសេដ្ឋកិច្ច និងអ្នកជំនួញ ចាប់ផ្តើមដកការគាំទ្រពី ប្រធានាធិបតី សាញ អេល អាប៊ីឌីន បិន អាលី ក៏ដូចជាកងកម្លាំងសន្តិសុខដែលមិនស្តាប់បញ្ជារបស់លោកប្រធានាធិបតី ឱ្យបាញ់រះលើក្រុមបាតុករដោយប្រើកាំភ្លើងយន្តដៃរ។

ជារឿងធម្មតាដែលសកម្មជនទាញយកការបំផុសគំនិត ពីអ្នកដទៃទៀតក្នុងស្ថានភាពស្រដៀងគ្នា ប៉ុន្តែការធ្វើបែបនេះអាចនឹងចេញលទ្ធផលជាការបរាជ័យទៅវិញ។ ឧទាហរណ៍ ខឹត វេឡែន នៃសាកលវិទ្យាល័យតិចសាស បានចង្អុលបង្ហាញថាក្នុងអំឡុងនៃរលកសកលដែលបដិវត្តភាគច្រើនគឺដោយហិង្សា ក្នុងឆ្នាំ១៨៤៨ ក្រុមអ្នកប្រឆាំងបានព្យាយាមប្រើប្រាស់យុទ្ធសាស្ត្រនៃការបះបោរដំបូង ប្រឆាំងនឹងរាជវង្សបារាំង ប៉ុន្តែបែរជាត្រូវបរាជ័យដោយសារតែការក្រុមរាជវង្សបានរៀបចំល្អជាង មានធនធានច្រើនជាង ដែលការពិតទៅមានប្រភេទនៃគូបដិបក្ខផ្សេងគ្នា។ ក្រោយមកទៀតក្នុងរលកនេះ ស្តេចទាំងអស់នេះអាចស្មានដឹងទុកមុននូវយុទ្ធសាស្ត្ររបស់ក្រុមបដិវត្តន៍ ហើយអាចបង្ក្រាបការបះបោរ និងបំបែកបំបាក់គូប្រជែងដើម្បីជាប្រយោជន៍ដល់ពួកគេ។ យើងអាចនឹងឃើញកម្លាំងស្រដៀងៗគ្នានេះក្នុងពេលបច្ចុប្បន្ន ជាពិសេស ក្នុងដំណាក់កាលក្រោយៗ នៃរលកការបះបោរថ្នាក់តំបន់។

## ៣. ប៉ុន្តែ ជឿឬមិនជឿ យុទ្ធនាការអហិង្សានៅតែទទួលបានជ័យជំនះច្រើនជងជាងការប្រើហិង្សា

បើនិយាយពីអត្រានៃភាពជោគជ័យ យុទ្ធនាការហិង្សាទទួលបានលទ្ធផលអាក្រក់ជាងយុទ្ធនាការអហិង្សាតាំងពីឆ្នាំ១៩៦០ មកម្លេះ។ តាមពិតទៅ បើមើលតួលេខសរុប ចាប់ពីឆ្នាំ១៩០០ ដល់ ឆ្នាំ២០១៥ យុទ្ធនាការអហិង្សាទទួលបានជោគជ័យ ៥១ ភាគរយ ធៀបនឹងយុទ្ធនាការទាំងអស់ក្នុងពេលនោះ ខណៈដែលយុទ្ធនាការហិង្សាទទួលជោគជ័យត្រឹមតែ ២៧ភាគរយនោះទេ។ មកទល់បច្ចុប្បន្នក្នុងទស្សវត្សរ៍នេះ មានយុទ្ធនាការអហិង្សាចំនួន ៣០ ភាគរយទទួលបានជោគជ័យ ខណៈដែលយុទ្ធនាការហិង្សាមានត្រឹមតែ ១២ ភាគរយប៉ុណ្ណោះ មានន័យថា ការពិតទៅ គម្លាតសមាមាត្រនៃអត្រាជោគជ័យរវាងយុទ្ធនាការទាំងពីរនេះ ធំជាងមធ្យមភាគទៅទៀត។

## ៤. ការធ្វើសកម្មភាពហិង្សាអមជាមួយ តែងតែបង្កទុក្ខទោសដល់ចលនាអហិង្សាទ្រង់ទ្រាយធំ

ប្រធានបទក្តៅគគុកមួយក្នុងចំណោមប្រធានបទផ្សេងៗ ចាប់តាំងពីឆ្នាំ២០១១មក គឺជាសំណួរពាក់ព័ន្ធនឹងថាតើការប្រើប្រាស់ហិង្សាបន្តិចបន្តួចអមជាមួយនឹងយុទ្ធនាការអហិង្សា អាចជួយដល់យុទ្ធនាការអហិង្សា ឬក៏ជះឥទ្ធិពលអាក្រក់ដល់យុទ្ធនាការអហិង្សាទៅវិញទេ។ សំណួរនេះតែងតែត្រូវបានលើកឡើងក្នុងការជជែកដេញដោលស្តីពី «ភាពចម្រុះនៃយុទ្ធសាស្ត្រ» ក្នុងសហរដ្ឋអាមេរិក។ ប៉ុន្តែសំណួរនៃវិធីសាស្ត្រអហិង្សា ហិង្សា ឬក៏វិធីសាស្ត្រចម្រុះ គឺត្រូវបានសួរជាញឹកញាប់ក្នុងចលនាដែលកំពុងតែស្វែងរកការផ្លាស់ប្តូរជាទូទៅ នៅលើពិភពលោក។ ថ្វីបើមានការអះអាងជាច្រើន ទាំងគុណសម្បត្តិ និងគុណវិបត្តិ ដោយអ្នកសង្កេតការណ៍ អ្នកជំនាញ ក៏ដូចជា សកម្មជនក៏ដោយ សំណួរនេះ បែរជាទទួលបានការវាយតម្លៃជាក់ស្តែងតិចតួចបំផុត រហូតទាល់តែថ្មីៗនេះ។

ក្នុងអត្ថបទថ្មីមួយក្នុង «ម៉ូប៊ីឡាហ្សេស៊ិន (ការកៀរគរ)» ឈើណូវិត និង ខឹត ហ្សរ៊ុក នៃសាកលវិទ្យាល័យរូតចឹប្រើប្រាស់ទិន្នន័យប្រៀបធៀបដើម្បីសិក្សាពីដែនកំណត់នៃការប្រើប្រាស់អំពើហិង្សា។ ពួកគេរកឃើញថា ការប្រើហិង្សាអមអាចនឹងទទួលបានគោលដៅដែលកំពុងដំណើរការក្នុងរយៈពេលខ្លី ដូចជា ការចាប់អារម្មណ៍ពីបណ្តាញសារព័ត៌មាន ទស្សនៈគិតថាដើម្បីការពារខ្លួន ការបន្សាយវប្បធម៌ប្រឆាំងដែលបង្កើតឱ្យមានសមាជិកទូទៅបន្ថែមទៀត ឬក៏ការបន្ធូរអារម្មណ៍ជុំវិញលទ្ធភាពក្នុងការ «បន្ថយអារម្មណ៍តានតឹង»។ ប៉ុន្តែការប្រើហិង្សាអម តែងតែផ្តល់ផលមិនល្អដល់គោលដៅយុទ្ធសាស្ត្ររយៈពេលវែង ដូចជាការរក្សា និងបង្កើនឱ្យមានមូលដ្ឋានចូលរួមកាន់តែទូលំទូលាយ និងចម្រុះ បង្កើនការគាំទ្ររបស់ភាគីទីបី និងទាក់ទាញឱ្យមានការប្តូរភក្តីភាពរបស់កងកម្លាំងសន្តិសុខ។ ពួកគេបានរកឃើញភស្តុតាងថា ការប្រើប្រាស់អំពើហិង្សាអម ជាធម្មតាមានអត្រាការចូលរួមតិចជាង និងមានការចូលរួមពីក្រុមដូចគ្នាកាន់តែច្រើន ដែលធ្វើឱ្យអន្តរាយដល់គុណសម្បត្តិចម្បង នៃការប្រើប្រាស់ការតស៊ូដោយអហិង្សាតាំងពីដំបូង។ ការស្រាវជ្រាវផ្សេងទៀត បានរកឃើញស្រដៀងគ្នាដែរថា ការប្រើហិង្សាអម អាចនឹងបង្កើនឱ្យមានការបង្ក្រាបពីរដ្ឋ ដែលតែងតែងជាប់ពាក់ព័ន្ធនឹងអត្រាការចូលរួមទាប។ ដូច្នេះ ជាមធ្យម ការប្រើប្រាស់ហិង្សាអមនេះ ច្បាស់ជាមិនជួយដល់យុទ្ធនាការអហិង្សាឲ្យទទួលជោគជ័យនោះទេ។

អូម៉ា វ៉ាសូ នៃសាកលវិទ្យាល័យ ព្រីនស្តុន បានផ្តល់នូវភស្តុតាងបន្ថែមទៀតពាក់ព័ន្ធនឹង ផលប៉ះពាល់ផ្នែកនយោបាយ នៃការធ្វើបាតុកម្មអហិង្សា ធៀបនឹងបាតុកម្មហិង្សា។ តាមរយៈការប្រើប្រាស់ទិន្នន័យ នៃការតវ៉ាប្រឆាំងក្នុងទីប្រជុំជនរបស់ជនជាតិអាមេរិកស្បែកខ្មៅ ក្នុងអំឡុងទស្សវត្សរ៍ទី៦០ វ៉ាសូ បានបង្ហាញថាចំនួនដងនៃការធ្វើបាតុកម្មដោយអហិង្សាកាន់តែច្រើន បាននាំឱ្យឈានដល់ការគាំទ្រយ៉ាងច្រើនដើម្បី «សិទ្ធិពលរដ្ឋ» ឱ្យក្លាយទៅជាបញ្ហាចម្បងនៃការព្រួយបារម្ភជាសាធារណៈនៅក្នុងសហរដ្ឋអាមេរិក ចំណែកឯចំនួនដងនៃការធ្វើបាតុកម្មដោយហិង្សាកាន់តែច្រើន បានបណ្តាលឱ្យមានការគាំទ្រច្រើនដល់ «ច្បាប់ និងសណ្តាប់ធ្នាប់» ឱ្យក្លាយជាបញ្ហាចម្បងទៅវិញ។ បន្ទាប់ពីឆ្នាំ១៩៦៥ ដោយសារតែបាតុកម្មហិង្សាកាន់តែមានលក្ខណៈទូទៅ គំនិតសាធារណជន បានប្តូរចេញពីការគាំទ្រលើសិទ្ធិពលរដ្ឋ និងបែរទៅគាំទ្រការឆ្លើយតបរបស់ប៉ូលីសទៅវិញ បង្ហាញឱ្យឃើញថាចលនា

ទាំងនេះបានបរាជ័យក្នុងការទាក់ទាញឱ្យមានការគាំទ្រ ពីសសរស្តម្ភដែលសំខាន់បំផុត។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺថាមតិសាធារណជនមិនមែនចាំបាច់តែក្នុងរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែក៏សំខាន់ក្នុងរយៈពេលវែងផងដែរៈ វ៉ាសូ រកឃើញថាការគាំទ្រ «ច្បាប់ និងសណ្តាប់ធ្នាប់» ទាក់ទងគ្នាយ៉ាងខ្លាំងជាមួយនឹងទំនោរបោះឆ្នោតឱ្យថ្នាក់ដឹកនាំសាធារណៈរដ្ឋ មានន័យថាលទ្ធផលនៃប្រភេទបាតុកម្មផ្សេងៗ បង្កឱ្យប៉ះពាល់យូរអង្វែងមកលើនយោបាយនៅក្នុងសហរដ្ឋអាមេរិក។

## ៥. ជម្លោះអហិង្សា គឺពិតជាពិបាកក្នុងការទស្សន៍ទាយខ្លាំងណាស់

វិស័យសង្គមវិទ្យាទាំងមូល មានការព្រួយបារម្ភជាយូរលង់ណាស់មកហើយទាក់ទងនឹងសំណួរថា តើចលនាសង្គមឬចលនាបាតុកម្មកើតឡើងនៅពេលណា។ យុទ្ធនាការតស៊ូដោយអហិង្សាបែបអតិបរមានិយម គឺមានភាពខុសគ្នាបន្តិចបន្តួច ដោយសារតែពួកគេសន្មតទុកជាមុននូវការរារាំងដ៏ខ្លាំងក្លា សកម្មភាពដែលមានការរៀបចំជាច្រើនដោយផ្តោតលើការប្រឆាំងគូប្រជែងដែលជារដ្ឋ ក្នុងគោលបំណងជាមូលដ្ឋានបំផុតគឺការផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននៅកម្រិតថ្នាក់ជាតិ។ ការសិក្សាបានវាយតម្លៃនូវមូលហេតុនៃការតស៊ូដោយអហិង្សា ដោយបានកំណត់នូវការជាប់ទាក់ទងគ្នាជាច្រើន ដូចជា ដង់ស៊ីតេនៃវិស័យផលិត (បាត់ធី និង ស្វិនសុន ២០១៤) អារម្មណ៍ (តែរមែន ២០១៣) ទីតាំងភូមិសាស្ត្រ (គ្លិតឌីធស៍ និងរីវ៉េរ៉ា ២០១៥) និងប្រវត្តិនៃបាតុកម្ម (ប្រេតវេត, ប្រេតវេត និង គូប៊ិក ២០១៥)។

ក្នុងឆ្នាំ២០១៥ ឈើណូវិត និង ចេយ៍ អ៊ុហ្វេលដេ បានវាយតម្លៃទ្រឹស្តី ទូទៅជាច្រើន នៃការងើបបះបោរទ្រង់ទ្រាយធំ ហើយបានរកឃើញថាទ្រឹស្តីមួយចំនួនតូចតែប៉ុណ្ណោះ ដែលអាចទស្សន៍ទាយយ៉ាងច្បាស់ថា ទីណាដែលនឹងមានយុទ្ធនាការអហិង្សាកើតឡើង។ ខុសពីយុទ្ធនាការដោយប្រើប្រដាប់អាវុធ រដ្ឋប្រហារ ឬក៏ការដួលរលំរបស់រដ្ឋ ដែលបញ្ញវន្តភាគច្រើនសុទ្ធតែអាចដឹងទុកជាមុនថា យុទ្ធនាការអហិង្សាទ្រង់ទ្រាយធំអាចកើតឡើងស្ទើរតែគ្រប់កន្លែង ដោយសារមូលហេតុផ្សេងៗ។ យុទ្ធនាការទាំងនោះកើតឡើងជារឿយៗក្នុងទីកន្លែងដែល បញ្ញវន្តរំពឹងថាការមានការលំបាកក្នុងការកៀរគរក្រុមដែលជំទាស់ ហើយការកៀរគរក្រុមជំទាស់នោះមានប្រសិទ្ធភាពតិចណាស់។ ហើយក៏មិនច្បាស់ដែរថាអ្វីដែលរុញឱ្យពួកគេធ្វើបែបនេះ ឬអ្វីដែលធ្វើឱ្យពួកគេនៅបន្តធ្វើវានោះ។ ឈើណូវិត និង អ៊ុហ្វេលដេ សន្និដ្ឋានថាចលនាអំណាចប្រជាពលរដ្ឋ គឺអាចកើតឡើងយ៉ាងសាមញ្ញបំផុតតាមបរិបទ និងដោយចៃដន្យ ដែលធ្វើឱ្យឧបករណ៍ប៉ាន់ប្រមាណ និងរចនាសម្ព័ន្ធទិន្នន័យមិនអាចកំណត់ឱ្យច្បាស់បានពីមូលហេតុនៃអំណាចនេះ។ វិធីមួយទៀតក្នុងការបកស្រាយរបកគំហើញនេះ គឺថាបុគ្គលដែលរៀបចំការបះបោរដោយអហិង្សាតែងតែជម្នះនូវលក្ខខណ្ឌមិនអំណោយផលជាច្រើនតាមវិធីច្នៃប្រឌិត ដែលមិនស្របតាមការរំពឹងទុក ហើយធ្វើឱ្យយើងមកដល់ចំណុចចុងក្រោយ។

## ៦. ការបង្ក្រាបគឺសំដៅលើយុទ្ធនាការប្រឆាំងទាំងអស់ ប៉ុន្តែមិនអាចកំណត់ទុកជាមុននូវជម្រើសនៃការតស៊ូអហិង្សា ឬលទ្ធផលនៃការតស៊ូនេះទេ

ការអះអាងដ៏មានប្រជាប្រិយភាពមួយអំពីការតស៊ូដោយអហិង្សា គឺថាវាអាចកើតឡើង និងប្រហែលជាអាចបានជោគជ័យប្រសិនបើគូប្រជែង ប្រកួតដោយស្មើភាព។ ប៉ុន្តែនៅពេលណាដែលគូប្រជែងដោះស្រោមដៃចេញ ការតស៊ូដោយអហិង្សាពិតជាមិនអាចទៅរួច ឬក៏គ្មានប្រយោជន៍នោះទេ។ យើងបានជជែកពីអំណះអំណាងនេះបន្តិចដែរក្នុងសៀវភៅរបស់យើង នៅឆ្នាំ២០១១ ប៉ុន្តែ ការងារថ្មីៗមួយចំនួនក៏បានលើកឡើងពីសំណួរដ៏សំខាន់នេះដែរ។

ចំណែកឯការលើកឡើងថា ការបង្ក្រាបយ៉ាងឃោរឃៅជះឥទ្ធិពលដល់លទ្ធភាពនៃការកើតឡើងនៃការតស៊ូដោយអហិង្សា វិនឌី កែរមែន បានអះអាងនៅក្នុងសៀវភៅដ៏អស្ចារ្យរបស់អ្នកស្រី អំពីចលនាជាតិនិយមរបស់ប៉ាលេស្ទីន ថាការបង្ក្រាបតែមួយមុខមិនអាចពន្យល់ថាតើមូលហេតុអ្វីដែលចលនាមួយនោះ អាចផ្លាស់ប្តូរពីសកម្មភាពអហិង្សាទៅជាហិង្សានោះទេ។ អ្នកស្រីបានលើកឡើងថា តាមពិតទៅការបង្ក្រាបមានសភាពតានតឹងក្នុងអំឡុងនៃដំណាក់កាលដំបូងនៃបាតុកម្មមានឈ្មោះថា អ៊ិនធីហ្វាដា ដែលដូចគ្នានឹងដំណាក់កាលមួយចំនួននៃចលនាហិង្សាដែរ។ ផ្ទុយទៅវិញ អ្នកស្រីបានលើកអំណះអំណាងថា កម្រិតនៃការរួបរួមគ្នាអាចពន្យល់បានយ៉ាងល្អបំផុតពាក់ព័ន្ធនឹងការប្រែក្លាយទៅជាហិង្សា។ នៅពេលដែលចលនាមួយមានទស្សនៈវិស័យ ភាពជាអ្នកដឹកនាំ និងមានបណ្តុំនៃវិធាន និងច្បាប់ រួមគ្នា ចលនានោះអាចពឹងផ្អែកលើការតស៊ូដោយអហិង្សា ទោះបីមានការបង្ក្រាបជាបន្តបន្ទាប់ដោយរដ្ឋាភិបាលអ៊ីស្រាអែលក៏ដោយ។
អ្នកស្រាវជ្រាវដូចជា ចូណាថាន់ ស៊ូគុន ឆាលស៍ បាត់ធឺ និង អ៊ីសាក់ ស្វិនសុន ក៏បានចង្អុលទៅរចនាសម្ព័ន្ធ និងការរៀបចំចលនា ថាជាការកំណត់ដ៏ចម្បងមួយនៃយុទ្ធនាការដែលទទួលជោគជ័យ នៅខណៈពេលដែលមានការបង្ក្រាប។ ពួកគេប្រើប្រាស់ទិន្នន័យបរិមាណ ដើម្បីអះអាងថានៅពេលដែលរដ្ឋប្រើប្រាស់អំពើហិង្សាតែមួយចំហៀង ឬក៏ការសម្លាប់រង្គាលមកលើបាតុករដែលគ្មានអាវុធ បាតុករអាចបន្តទៅរកភាពជោគជ័យបានក្នុងរយៈពេលវែងដរាបណាដែលពួកគេគឺជាផ្នែកមួយនៃយុទ្ធនាការដ៏ធំ និងបានរៀបចំយ៉ាងល្អ។

ពិតណាស់ ការស្រាវជ្រាវមួយចំនួនបានដាក់ការសង្ស័យទៅលើលទ្ធភាពនៃការប្រឆាំងដោយអហិង្សា ក្នុងការតតាំងនឹងរបបគាបសង្កត់ដែលទំនើបខ្លាំង ជាពិសេស របបដែលមានមហិច្ឆិតាប្រល័យពូជសាសន៍ ឬផ្នែកនយោបាយ។ ការងារថ្មីៗរបស់ លោក គ្រីស្តូហ្វ័រ ស៊ូលីវ៉ាន់ អំពីទង្វើរបស់កងកម្លាំងសន្តិសុខហ្គាតេម៉ាឡា ក្នុងការដកចេញជាប្រព័ន្ធនូវគូបដិបក្ខឆ្វេងនិយម ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ១៩៨៥ គឺជារឿងរ៉ាវដ៏គួរឱ្យប្រុងប្រយ័ត្នមួយទាក់ទងនឹងភាពទំនើប និងការប្តេជ្ញាចិត្តដែលរបបខ្លះបានបង្កើត។ ដូចគ្នានឹងអំពើឃោរឃៅ ការសម្លាប់ដែលត្រូវបានគណនា មកលើក្រុមបាតុករអហិង្សាដោយរបប បាសា អាល់ អាសាដ នៅប្រទេសស៊ីរី បន្ទាប់ពីការតវ៉ានៅឌឺរ៉ាក្នុងខែមីនា ឆ្នាំ ២០១១ ជាការរំលឹកដ៏គួរឱ្យព្រួយបារម្ភមួយអំពីមូលហេតុ ដែលចំនួននៃយុទ្ធនាការអហិង្សាទ្រង់ទ្រាយធំត្រូវបរាជ័យញឹកញាប់ ដូចចំនួនដែលបានទទួលជោគជ័យដែរ។

ប៉ុន្តែ ជាថ្មីម្តងទៀត វាពិតជាពិបាកក្នុងការទស្សន៍ទាយ នៅពេលដែលការិយាធិបតេយ្យដែលមានលក្ខណៈគាបសង្កត់បែបនេះ អាចនឹងបង្ខំឱ្យអ្នកក្រោមបង្គាប់របស់ពួកគេស្មោះត្រង់ប្តូរផ្តាច់ នៅក្នុងការបះបោរទ្រង់ទ្រាយធំសូម្បីតែក្នុងករណីដែលហាក់ដូចជាមិនអាចទៅរួចដូចជានៅប្រទេសស៊ីរី ជាដើម។ បន្ថែមពីលើនោះ នៅក្នុង

ការងារដែលនឹងចេញផ្សាយនាពេលខាងមុខ លី ស្មីតថី លេស្ទ័រ ខឹត និងអ្នករួមចំណែកដទៃទៀត រកឃើញថាការបង្ក្រាបរបស់របបមកលើបាតុករដែលគ្មានអាវុធ អាចនឹងបង្ករឱ្យមានការខឹងសម្បារជាញឹកញាប់ ដោយបង្កើតឱ្យមានការខឹងសម្បារផ្នែកសីលធម៌ បណ្ដាលឱ្យមានការចូលរួមកាន់តែច្រើន បង្កើតឱ្យមានការគាំទ្រពីភាគីទីបីចំពោះចលនា និងធ្វើឱ្យកងកម្លាំងសន្តិសុខចូលរួមជាមួយក្រុមបាតុករ។ ការពិតទៅ ការគាបសង្កត់ជាច្រើន ជាញឹកញយអាចជាមូលហេតុនៃយុទ្ធនាការអហិង្សា ជាជាងជាចំណុចបញ្ចប់នៃយុទ្ធនាការអហិង្សា។ ការសម្លាប់ អេមេត ធីលគឺជាឧទាហរណ៍នៃអំពើហិង្សាដែលគួរឱ្យរន្ធត់ ដែលជាលទ្ធផលធ្វើឱ្យមានការកើនឡើងនៃការគាំទ្រ ការអាណិតអាសូរ និងការចូលរួមក្នុងចលនាទាមទារសិទ្ធិពលរដ្ឋរបស់សហរដ្ឋអាមេរិក។

ដោយពិចារណាដល់ទិវារំលឹក លោក ម៉ាទីន លូទ័រ ឃីង យើងគិតថាយើងនឹងផ្ដល់ឱ្យអ្នកអាននូវផ្នែកដែលពោរពេញដោយគំនិត ចេញពី «លិខិតពីពន្ធនាគារប៊ីរមីងហែម» របស់លោក ហើយអត្ថបទពេញ អ្នកអាចអានបាននៅទីនេះ ៖

«ឱសម្លាញ់អើយ! ខ្ញុំគួរតែប្រាប់អ្នកថាយើងពុំបានទទួលបានផលចំណេញណាមួយ ក្នុងការទាមទារសិទ្ធិពលរដ្ឋប្រសិនបើគ្មានគំនាបអហិង្សា និងផ្នែកច្បាប់ដ៏រឹងមាំនោះទេ។ គួរឱ្យសោកស្ដាយ វាគឺជាការពិតផ្នែកប្រវត្តិសាស្ត្រដែលថាក្រុមដែលទទួលបានសិទ្ធិពិសេស កម្រនឹងបោះបង់សិទ្ធិពិសេសនោះដោយស្ម័គ្រចិត្តណាស់។ បុគ្គលអាចនឹងមើលឃើញនូវពន្លឺសីលធម៌ ហើយស្ម័គ្រចិត្តក្នុងការបោះបង់ចោលនូវឥរិយាបថអយុត្តិធម៌របស់ពួកគេ ប៉ុន្តែដូចរេណុល ណេប៊ រ បានដាស់តឿនយើងស្រាប់ថា ក្រុមមានទំនោរអសីលធម៌ជាងបុគ្គល។ យើងដឹងតាមរយៈបទពិសោធន៍ដ៏ឈឺចាប់ថា សេរីភាពមិនដែលត្រូវបានផ្ដល់ឱ្យដោយអ្នកគាបសង្កត់គេដោយស្ម័គ្រចិត្តនោះទេ ប៉ុន្តែសេរីភាពត្រូវតែទាមទារយកមកដោយបុគ្គលដែលរងការគាបសង្កត់។»

ពិតណាស់ ឃីង ព្រួយបារម្ភទាំងផ្នែកសីលធម៌ និងតថភាពជាក់ស្ដែងនៃការតស៊ូដោយអហិង្សា។ ប៉ុន្តែ ភាពប្រាកដនិយមរបស់គាត់មិនគួរត្រូវបានមើលស្រាលនោះទេ ស្របពេលដែល សៀវភៅរបស់ ចនណាថាន់ រ៉ៃឌ័រ អំពីលិខិតមកពីប៊ីរមីងហែម ស្ដីពីកូដកម្មមកផ្ទះវិញ។

ច្បាស់ណាស់ មានរឿងជាច្រើនដែលត្រូវរៀនអំពីការតស៊ូដោយអហិង្សា៖ វាជាបាតុភូតដែលកំពុងតែលេចឡើង ហើយការស្រាវជ្រាវលើប្រធានបទនេះ ក៏កំពុងតែលេចធ្លោឡើងក្នុងវិទ្យាសាស្ត្រសង្គមផងដែរ។ មនុស្សម្នា កំពុងតែចង់តតាំងនឹងការគាបសង្កត់ អាចនឹងទទួលបានផលប្រយោជន៍ពីការស្រាវជ្រាវជាប្រព័ន្ធ អំពីពេលណា និងរបៀបណា ក្នុងការធ្វើការតស៊ូដោយអហិង្សាក្នុងបរិបទផ្សេងៗគ្នាជាច្រើន។ អ្នកធ្វើគោលនយោបាយ ដែលកំពុងតែដោះស្រាយ នឹងបញ្ហាប្រឈមដែលកើតឡើង មានដូចជា ការកើតឡើងវិញនៃអំណាចផ្ដាច់ការ ឬក៏ភាពផុយស្រួយរបស់រដ្ឋ ឬក៏អំពើហិង្សាជ្រុលនិយម អាចនឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីការយល់ឱ្យបានស៊ីជម្រៅអំពីពេលណា និងហេតុអ្វីចលនាអហិង្សាទទួលបានជោគជ័យ ហើយតើវាមានន័យដូចម្ដេចក្នុងការគាំទ្រចលនានេះឱ្យមានប្រសិទ្ធភាព។

ក្នុងទស្សវត្សរ៍នេះ ដែលមនុស្សជាច្រើនកំពុងតែអនុវត្តការតស៊ូអហិង្សាជាងពេលណាៗទាំងអស់ បញ្ញវន្ត ក៏ដូចជាអ្នកអនុវត្តផ្ទាល់អាចនឹងទទួលបានលទ្ធផលល្អ ប្រសិនបើបានពិចារណាលើប្រាជ្ញាដែលមានគោលការណ៍ និងប្រាកដនិយម របស់គន្ធី និងឃីង ក្នុងការធ្វើការងារទៅខាងមុខបន្តទៀត។

*អេរីកា ឈើណូវិត ជាសាស្ត្រាចារ្យ នៃសាលាចូសេហ្វ កូបេល ផ្នែកសិក្សាអន្តរជាតិ នៃសាកលវិទ្យាល័យ ដេនវើ។ អ្នកស្រី ជាសហអ្នកនិពន្ធនៃប្លុកឈ្មោះថា ការក្រឡេកមើលលើអំពើហិង្សានយោបាយ ហើយក៏ជាអ្នកនិពន្ធម្តងម្កាលនៃប្លុក ម៉ាងឃី ខេច។ ម៉ារៀ ជេ. ស្ទេហ្វេនគឺជាសមាជិកជាន់ខ្ពស់នៅវិទ្យាស្ថានសន្តិភាពសហរដ្ឋអាមេរិក និងជាសមាជិកជាន់ខ្ពស់នៅឯក្រុមប្រឹក្សាអាត្លង់តិក។*